# ស្ថានភាពអតិផរណានៅខែតុលា ឆ្នាំ២០១៨

## ក/ អតិផរណាក្នុងប្រទេស

តាមប្រភពទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិ (NIS) បានបង្ហាញថា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែតុលា មានការកើនឡើង **០,៣%** ធៀបនឹងខែមុន និង **៣,១%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្នុងខែតុលា ឆ្នាំ២០១៨នេះ សន្ទស្សន៍ថ្លៃទំនិញភាគច្រើនមានការកើនឡើងធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះសន្ទស្សន៍ថ្លៃក្រុមទំនិញអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹងកើន ៣,២%, ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់កើន ២,៥%, សម្លៀកបំពាក់និងស្បែកជើងកើន ៣,០%, ការដឹកជញ្ជូនកើន ៤,១% និងភោជនីយដ្ឋានកើន ៦,០%។ តាមការសង្កេត **សន្ទស្សន៍ថ្លៃក្រុមទំនិញអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹងហាក់មាននិន្នាការកើនឡើងវិញ បន្ទាប់ពីមានកំណើនថមថយចាប់ពីដើមឆ្នាំ២០១៨មក,** ក្នុងរយៈពេល ៣ខែចុងក្រោយនេះ សន្ទស្សន៍ថ្លៃក្រុមទំនិញអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹងមានកំណើនជាមធ្យម ២,៨% ក្នុងនោះ សន្ទស្សន៍ថ្លៃអង្ករមានកំណើនជាមធ្យម ២,៨%, ត្រីទឹកសាបនិងសមុទ្រមានកំណើន ៣,៩%, សាច់មានកំណើន ២,៨% និងបន្លែមានកំណើន ៤,៤%។

***គិតត្រឹមខែតុលា អតិផរណាមធ្យមប្រចាំឆ្នាំ (year average) មានអត្រា ២,៥% ទាបជាងអត្រាក្នុងខែដូចគ្នាឆ្នាំ ២០១៧ ដែលមានអត្រា ៣,២%។*** តាមការធ្វើចំណោលដល់ខែធ្នូ ឆ្នាំ២០១៨[១] អតិផរណាប្រចាំឆ្នាំ (year on year) អាចនឹងមានអត្រា ២,៨% និង អតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចនឹងមានអត្រា ២,៦%។

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **+០,៣** | **+៣,១** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | +០,២ | +៣,២ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +១,០ | +២,៥ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | +០,០ | +៣,០ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | +០,៤ | +១,៦ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | +០,២ | +០,៤ |
| ៦-សុខាភិបាល | +០,៣ | +១,៧ |
| ៧-ការដឹកជញ្ជូន | +០,៦ | +៤,១ |
| ៨-គមនាគមន៍ | +០,៣ | -០,៣ |
| ៩-ការកំសាន្ត និងវប្បធម៌ | +០,៤ | +១,១ |
| ១០-ការសិក្សា | ០,០ | +០,៤ |
| ១១-ភោជនីយដ្ឋាន | +០,៥ | +៦,០ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | -០,២ | +១,៧ |

[១] ការធ្វើចំណោលដល់ខែធ្នូ ឆ្នាំ២០១៨÷ គឺជាការធ្វើចំណោលដោយយោងលើអត្រាកំណើនជាមធ្យមប្រចាំខែ (month on month)នៃសន្ទស្សន៍ថ្លៃទំនិញ ក្នុងរយៈពេល ៣ឆ្នាំ ចុងក្រោយ។

| តារាងបម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបនឹងខែមុន (%) | | | ធៀបនឹងឆ្នាំមុន (%) | | |
| | ២០១៨ | | | ២០១៨ | | |
| | សីហា | កញ្ញា | តុលា | សីហា | កញ្ញា | តុលា |
| អង្ករ | +០,៩ | +០,១ | +០,២ | +២,៨ | +២,៧ | +២,៩ |
| សាច់គោ | +០,៤ | +០,២ | -០,១ | +២,៦ | +២,១ | +២,២ |
| សាច់មាន់ | +០,៥ | ០,០ | +០,២ | +១,៨ | +២,០ | +១,៧ |
| សាច់ទា | -០,៥ | +០,១ | +០,៧ | +០,១ | +១,៩ | +២,១ |
| សាច់ជ្រូក | +២,០ | +០,៥ | -០,៦ | +៣,០ | +៣,៤ | +៣,៥ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | +០,៨ | +០,៥ | +០,១ | +៤,៦ | +៣,២ | +៤,១ |
| ក្នុងនោះត្រីស្រស់ | +០,៨ | +០,៧ | ០,០ | +៤,៧ | +៣,២ | +៤,៣ |
| ផ្លែឈើ | +០,២ | -០,៥ | +០,៨ | +២,៣ | +១,៧ | +២,៥ |
| ផ្លែឈើស្រស់ | +០,៣ | -០,៧ | +០,៩ | +២,៣ | +១,៦ | +២,៥ |
| បន្លែ | +១,១ | +១,៥ | +០,៥ | +២,៨ | +៤,៣ | +៥,៩ |
| បន្លែជាស្លឹក | +០,៥ | +១,៨ | +១,៥ | +៥,០ | +៧,៥ | +១០,៦ |
| បន្លែជាផ្លែ | +២,៣ | +២,៨ | -០,៤ | +២,២ | +៥,៧ | +៥,៤ |

## ១/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | | | |
|---|---|---|---|---|---|---|
| ប្រទេស | ២០១៧ | | | ២០១៨ | | |
| | សីហា | កញ្ញា | តុលា | សីហា | កញ្ញា | តុលា |
| ប្រទេសកម្ពុជា | 2.6 | 2.7 | 2.1 | 2.6 | 2.6 | 3.1 |
| ប្រទេសវៀតណាម | 3.4 | 3.4 | 3.0 | 4.0 | 4.0 | 3.9 |
| ប្រទេសថៃ | 0.3 | 0.9 | 0.9 | 1.6 | 1.3 | 1.2 |
| ប្រទេសម៉ាឡេស៊ី | 3.7 | 4.3 | 3.7 | 0.2 | 0.3 | 0.6 |
| ប្រទេសឥណ្ឌូនេស៊ី | 3.8 | 3.7 | 3.6 | 3.2 | 2.9 | 3.2 |
| ប្រទេសហ្វីលីពីន | 2.7 | 3.1 | 3.5 | 6.4 | 6.7 | 6.7 |
| ប្រទេសចិន | 1.8 | 1.6 | 1.9 | 2.3 | 2.5 | 2.5 |
| ប្រទេសកូរ៉េខាងត្បូង | 2.6 | 2.1 | 1.8 | 1.4 | 1.9 | 2.0 |
| ប្រទេសជប៉ុន | 0.7 | 0.7 | 0.2 | 1.3 | 1.2 | 1.4 |

ប្រភពទិន្នន័យ
(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)
(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

## កំណត់សម្គាល់

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមភេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ (+៨៥៥) ២៣ ៤២៧ ៩១៣, (+៨៥៥) ៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្ដែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*